មាត្រា ១០ :ទីតាំងសាលេ... ស្ថិតនៅក្នុងសង្កាត់ស្ទឹងត្រង់ ។

មាត្រា ១១ :បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២ :នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល សហរដ្ឋមន្ត្រីទទួល ...ការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវ ទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ១៣ :ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១...

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គា...

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

* * *

## II-រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

**អនុក្រឹត្យលេខ : ៣៣ អនក្រ.បក**

**ស្តីពី**

**ការត្រួតពិនិត្យហិរញ្ញវត្ថុនិងបទបញ្ជាផ្ទៃនៅ**

**នៃគណនេយ្យសាធារណៈ ក្រសួងការពារជាតិ**

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល ចំពោះរាល់ការចំណាយរបស់ក្រសួងការពារជាតិ

## សំរេច

ប្រការ ១ : អនុក្រឹត្យនេះកំណត់នូវកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ អំពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ការត្រួតពិនិត្យហិរញ្ញវត្ថុ និងការងារលទ្ធកម្មសាធារណៈសំរាប់ការគ្រប់គ្រងថវិកាក្រសួងការពារជាតិ ដែលជាមុខសញ្ញាចំណាយមានលក្ខណៈពិសេសនិងចាំបាច់ ត្រូវមានការគ្រប់គ្រងដោយឡែក ។

## ជំពូក ១

## បទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ

មាត្រា ២ : ...រដ្ឋមន្ត្រីក្រសួងការពារជាតិ គឺជាអាណាប័កដើមខ្សែនៃចំណូល និងចំណាយ ...របស់ក្រសួងការពារជាតិ ។ ...អាណាប័កដើមខ្សែនៃក្រសួងការពារជាតិអាច ជ្រើសរើសយកនាយទាហានជាន់ខ្ពស់ ផ្នែកជំនាញហិរញ្ញវត្ថុ ដែលមានការទទួលខុស ត្រូវខ្ពស់ ហើយដែលស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ខ្លួន អោយធ្វើជាអាណាប័ក ផ្ទេរសិទ្ធិ ។

មាត្រា ៣ : ការបង្កើតនិងការតែងតាំងរដ្ឋទេយ្យករ និង ភ្នាក់ងារបើកផ្តល់ ត្រូវបានធ្វើឡើង ដោយប្រកាស អន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងការពារជាតិ ។

មាត្រា ៤ : ថវិកាការពារជាតិ ត្រូវបានគ្រោងឡើងតាមសំណូមពរ ភារកិច្ចនិងតាមលទ្ធភាព ថវិការដ្ឋ ដោយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។ ក្នុងករណីការ ចំណាយថវិកាសំរាប់ការទិញ ផលិត ជួសជុលយោធោបករណ៍ធំៗនិងការចំណាយ តាមបទបញ្ជារបស់រាជរដ្ឋាភិបាល ដែលមានលក្ខណៈសំងាត់ ហើយដែលមិនមាន គ្រោងទុកនៅក្នុងផែនការថវិកាប្រចាំឆ្នាំ ត្រូវពិនិត្យពិចារណាយ៉ាងម៉ត់ចត់ដោយ ក្រសួងការពារជាតិ និង មានការចូលរួមយោបល់ចាំបាច់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ វត្ថុ ហើយត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល ទើបអាចចុះកិច្ចសន្យាបាន ។ ការ ទូទាត់ត្រូវអនុវត្តតាមប្រការដូចមានចែងក្នុងកិច្ចសន្យា ដោយកត់ត្រាក្នុងខ្ទង់ចំណាយ របស់ក្រសួងការពារជាតិ ។

មាត្រា ៥ : ស្ថិតក្នុងរង្វង់ឥណទានថវិកាដែលសភាបានអនុម័ត អាណាប័កក្រសួងការពារជាតិ ចេញអាណត្តិដោយមិនបាច់ភ្ជាប់នូវលិខិតយុត្តិការចំពោះមុខចំណាយណាដែលមាន លក្ខណៈសំងាត់ទៅអោយមន្ត្រីអភិបាលហិរញ្ញវត្ថុនិងគណនេយ្យករ «រតនាគារជាតិ» ទេ ។ គ្រប់ឯកសារចំណាយសំងាត់ត្រូវតំកល់ទុកនៅនាយកដ្ឋានថវិកា ក្រសួងការ ពារជាតិ ។ ករណីមានបាតុភាពកើតឡើងពីការចំណាយសំងាត់នេះ ឯកសារនោះ ត្រូវចាំបាច់អនុញ្ញាតអោយអ្នកមានសមត្ថកិច្ចធ្វើការពិនិត្យ ហើយសហរដ្ឋមន្ត្រី ក្រសួង ការពារជាតិត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។ ចំពោះមុខចំណាយដែល

មានលក្ខណៈធម្មតា ដូចជា ឯកសណ្ឋាន និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ ទឹកភ្លើង ទូរស័ព្ទ ថ្នាំពេទ្យ ប្រេងឥន្ធនៈ សៀង ត្រូវភ្ជាប់តាមនូវ លិខិតយុត្តិការធ្វើអោយមន្ត្រីអភិបាលហិរញ្ញវត្ថុ និង រតនាគារជាតិ ។

**មាត្រា ៦ :** ករណីខ្ទង់ឥណទានថវិកាណាមួយដែលមិនអាចធានាបានគ្រប់គ្រាន់ ដោយនុលោមតាមច្បាប់ជាធរមាន ក្រសួងការពារជាតិ អាចសុំធ្វើការបង្វែរ ឬ ផ្ទេរខ្ទង់ឥណទានទំនេរផ្សេងៗ ទៀតមកបំពេញ ឬ សុំថវិកាបន្ថែម និងបញ្ចូលក្នុងច្បាប់កែតំរូវថវិកាប្រចាំឆ្នាំដែលរៀបចំ ឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៧ :** ការទិញ ផលិត ឬ ការជួសជុលបរិក្ខារនិងយោធូបករណ៍ក្នុងកងយោធពលខេមរភូមិន្ទ អាចប្រព្រឹត្តទៅបាន នៅក្នុងវង្វង់ឥណទានទំនេរដោយអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធី លទ្ធកម្មសាធារណៈ ។

**មាត្រា ៨ :** ការទូទាត់គឺជាកិច្ចប្រតិបត្តិការ ដែលធ្វើឡើងដោយអាណាប័កក្រសួងការពារជាតិ តាមនីតិវិធី ហិរញ្ញវត្ថុសាធារណៈ ។

## ជំពូក ២

## ការត្រួតពិនិត្យនិងមន្ត្រីអភិបាលហិរញ្ញវត្ថុ

**មាត្រា ៩ :** ការគ្រប់គ្រងថវិការបស់ក្រសួងការពារជាតិ គឺជាកិច្ចការសំងាត់ ។ បណ្តាលិខិតយុត្តិការដែលបញ្ជាក់អំពីការចំណាយសំងាត់ត្រូវបានកសាងសំរាប់តែៈការពិនិត្យសំរេច ពីអាណាប័កក្រសួងការពារជាតិ ហើយត្រូវតំកល់ទុកនៅនាយកដ្ឋានថវិកា ក្រសួងការពារជាតិ ។ រីឯការពិនិត្យចុះទិដ្ឋាការរបស់មន្ត្រីអភិបាលហិរញ្ញវត្ថុ គឺអាចធ្វើបានតែលើសាលាកប័ត្រកត់ត្រាចំណាយនិង អាណត្តិបើកប្រាក់តែប៉ុណ្ណោះ លើកលែងតែការចំណាយប្រក្រតី ដូចមានចែងក្នុងមាត្រា៥ ត្រូវប្រតិបត្តិតាមកិច្ចសន្យា ។

**មាត្រា ១០ :** មន្ត្រីអភិបាលហិរញ្ញវត្ថុប្រចាំក្រសួងការពារជាតិ គឺត្រូវជ្រើសរើសយ៉ាងម៉ត់ចត់ ដើម្បីធានាបានទាំងស្រុងនូវការរក្សាការសំងាត់ ។

## ជំពូក ៣

## ការគ្រប់គ្រងលទ្ធកម្មសាធារណៈ

មាត្រា១១ : ការងារលទ្ធកម្មសាធារណៈរបស់ក្រសួងការពារជាតិ ទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រី ដោយប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃចុះកិច្ចសន្យា PEAC និង មានអង្គភាពលទ្ធកម្មសាធារណៈជាជំនួយការ ។

មាត្រា១២ : រាល់កិច្ចលទ្ធកម្មទំនិញជាប្រក្រតី ត្រូវអនុវត្តឆ្លងកាត់តាមអង្គភាពលទ្ធកម្ម និងគណៈកម្មការ PEAC ជាអ្នករៀបចំលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិពិនិត្យសំរេច ។

## ជំពូក ៤

## អវសានបញ្ញត្តិ

មាត្រា១៣ : គោលការណ៍ចំបងនៃអនុក្រឹត្យនេះ គឺសំដៅសំរបសំរួល ដើម្បីជំរុញការគ្រប់គ្រងឥណទានថវិកាក្រសួងការពារជាតិ អោយដំណើរការអនុវត្តមានភាពប្រសើរ និងធានាបាននូវសុវត្ថិភាព ភារកិច្ចការពារជាតិ ។

មាត្រា១៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**ហ៊ុន សែន**